# សេចក្តីថ្លែងការណ៍
## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ស្តីពី
## សាលដីការបស់តុលាការយុត្តិធម៌អន្តរជាតិ លើបណ្តឹងសុំរបស់កម្ពុជា
## ឱ្យបកស្រាយសាលដីកា ឆ្នាំ ១៩៦២ ពាក់ព័ន្ធនឹងរឿងក្តីប្រាសាទព្រះវិហារ
## រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣

****+****

**ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ !**
**ជនរួមជាតិជាទីគោរពស្នេហា !**

នារសៀលថ្ងៃទី ១១ វិច្ឆិកា ឆ្នាំ ២០១៣ នេះ តុលាការយុត្តិធម៌អន្តរជាតិ (ICJ) នាទីក្រុងឡាអេ, ប្រទេសហូឡង់, បានប្រកាសចេញនូវសាលដីការបស់ខ្លួន លើបណ្តឹងសុំរបស់ព្រះរាជាណាចក្រកម្ពុជា ឱ្យបកស្រាយលើសាលដីកា ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៦២ ពាក់ព័ន្ធនឹងរឿងក្តីប្រាសាទព្រះវិហារ ដែលមានខ្លឹមសារ ដូចតទៅ: **«តុលាការ ÷**

**១- ប្រកាសដោយសម្លេងឯកច្ឆន្ទថាតុលាការមានសមត្ថកិច្ច ដោយផ្អែកតាមមាត្រា ៦០ នៃលក្ខន្តិកៈរបស់ខ្លួនដើម្បីសម្រេចលើបណ្តឹងសុំបកស្រាយសាលដីកាឆ្នាំ ១៩៦២ ដែលប្តឹងសុំដោយព្រះរាជាណាចក្រកម្ពុជា ហើយទទួលស្គាល់ថា បណ្តឹងសុំនេះ អាចទទួលយកមកពិនិត្យដោះស្រាយបាន ។**

**២- ប្រកាសដោយសម្លេងឯកច្ឆន្ទថា ក្នុងក្របខ័ណ្ឌនៃការបកស្រាយសាលដីកាចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ១៩៦២ តុលាការសម្រេចនៅក្នុងសាលដីកានេះថា ព្រះរាជាណាចក្រកម្ពុជាមានអធិបតេយ្យពេញលេញលើបូរណភាពទឹកដីលើតំបន់ពយភ្នំ (Eperon/Promontory) នៃប្រាសាទព្រះវិហារ ដូចដែលមានកំណត់ក្នុងកថាខ័ណ្ឌទី ៩៨ នៃសាលដីកានេះ ហើយជាបច្ច័យ តុលាការប្រកាសថា ព្រះរាជាណាចក្រថៃមានកាតព្វកិច្ចដកចេញពីទឹកដីនេះ នូវគ្រប់កងកម្លាំងប្រដាប់អាវុធ ឬកងនគរបាល ឬអ្នកថែរក្សា ឬឆ្មាំយាម ផ្សេងទៀតរបស់ថៃ ដែលបោះទីតាំងនៅក្នុងទឹកដីនោះ»** ។

ខ្ញុំព្រះករុណា ខ្ញុំ សូមបញ្ជាក់បន្ថែមថា កថាខ័ណ្ឌទី ៩៨ នៃសាលដីកានេះ បានបញ្ជាក់យ៉ាងច្បាស់អំពីការកំណត់ទីតាំងនៃតំបន់ពយភ្នំនេះ ។

នេះ គឺជាជំហានទៅមុខដ៏មានសារៈសំខាន់ និងមានអត្ថន័យជាប្រវត្តិសាស្ត្រមួយទៀត នៅក្នុងការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅដោះស្រាយដោយសន្តិវិធី និង ផ្អែកលើច្បាប់អន្តរជាតិ នូវវិវាទរវាងកម្ពុជា និង ថៃ លើបញ្ហាប្រាសាទព្រះវិហារ និងតំបន់ជុំវិញប្រាសាទនេះ ។ ជាពិសេស ការណ៍ដែលតុលាការយុត្តិធម៌អន្តរជាតិយកផែនទីឧបសម្ព័ន្ធ ១ ខ្នាត ១/២០០ ០០០ ដែលភាគីកម្ពុជាបានដាក់ជូនតុលាការនៅឆ្នាំ ១៩៦២ មកធ្វើជាសម្អាងក្នុងការបកស្រាយធ្វើសេចក្តីសម្រេចរបស់ខ្លួន ពិតជានឹងផ្តល់ភាពច្បាស់លាស់ដ៏សំខាន់បំផុតដល់ភាគីទាំងពីរសម្រាប់ការអនុវត្តបន្ត ។

លើមូលដ្ឋាននេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំព្រះករុណា ខ្ញុំ សូមសង្កត់ធ្ងន់ជាថ្មីម្តងទៀត, បន្ថែមលើសេចក្តីថ្លែងការណ៍របស់ខ្ញុំព្រះករុណា ខ្ញុំ ជូនជនរួមជាតិ កាលពីថ្ងៃទី ៧ វិច្ឆិកា កន្លងទៅ, អំពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការប្រកាន់ខ្ជាប់នូវជំហររួម ដែលខ្ញុំព្រះ-ករុណា ខ្ញុំ ក្នុងនាមជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវ **យីងឡាក់ ស៊ីនណាវ៉ាត្រា** នាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រថៃ បានឯកភាពគ្នាកន្លងមកថាៈ **«ទោះបីជាសាលដីកានៃតុលាការយុត្តិធម៌អន្តរជាតិ នាថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ នេះ ចេញមកបែបណាក៏ដោយ ក៏ប្រទេសទាំងពីរ ត្រូវតែគោរពតាមសេចក្តីសម្រេចនេះ ហើយខិតខំថែរក្សាឱ្យខាងតែបាននូវមិត្តភាពរវាងប្រទេស និង ប្រជាជនទាំងពីរ ព្រមទាំងសន្តិភាព និងស្ថិរភាព នៅតាមបណ្តោយព្រំដែនកម្ពុជា- ថៃ»** ។ ជាមួយនឹងការប្តេជ្ញាចិត្តដ៏មុតមាំនេះ ខ្ញុំព្រះករុណា ខ្ញុំ សូមគូសបញ្ជាក់បន្ថែមទៀតថា រាជរដ្ឋាភិបាលកម្ពុជានឹងគោរព ព្រមទាំងអនុវត្តតាមស្មារតីនៃកិច្ចប្រជុំរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសទាំងពីរ, កម្ពុជា និង ថៃ, នាថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១៣ កន្លងទៅថ្មីៗនេះ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលភាគីទាំងសងខាងបានឯកភាពគ្នាថា នឹងបន្តកិច្ចពិភាក្សានៅក្នុងក្របខ័ណ្ឌនៃយន្តការមានស្រាប់ ដើម្បីជំរុញអនុវត្តសាលដីការបស់តុលាការយុត្តិធម៌អន្តរជាតិ ដោយក្នុងនេះ រដ្ឋាភិបាលទាំងសងខាង ប្តេជ្ញាមិនធ្វើសកម្មភាពណាមួយដែលនាំឱ្យមានភាពតានតឹងរវាងប្រទេសទាំងពីរ និង ប្តេជ្ញាទប់ស្កាត់មិនឱ្យជនណាមួយបង្កសកម្មភាពដែលនាំឱ្យមានភាពតានតឹងរវាងប្រទេសទាំងពីរ ព្រមទាំងផ្តល់ការយកចិត្តទុកដាក់ជាពិសេសលើការរក្សា និងពង្រឹងពង្រីកទំនាក់ទំនងជាមិត្តភាព និងសហប្រតិបត្តិការល្អរវាង

ប្រទេសទាំងពីរ, ចៀសវាងការប៉ះទង្គិចដល់ការធ្វើចរាចរទៅវិញទៅមករបស់ប្រជាជនទាំងសងខាង, ការផ្លាស់ប្តូរពាណិជ្ជកម្ម និងការវិនិយោគ, ការដឹកជញ្ជូន និងកិច្ចសហប្រតិបត្តិការផ្សេងៗទៀត ។

ទូលព្រះបង្គំជាខ្ញុំសូមយកឱកាសនេះ ដើម្បីសំដែងនូវការរំឮកដឹងគុណដ៏ជ្រាលជ្រៅជាទីបំផុត ឧទ្ទិសថ្វាយព្រះវររាជបិតាជាតិ ព្រះបរមរតនៈកោដ្ឋ សម្តេចព្រះ **នរោត្តម សីហនុ** ដែលព្រះអង្គទ្រង់បានបន្សល់នូវមរតកជាប្រវត្តិសាស្ត្រដ៏មហាថ្លៃថ្លា ដល់កូនចៅជំនាន់ក្រោយសម្រាប់ធ្វើជាសម្អាងបន្តដោះស្រាយបញ្ហាប្រាសាទព្រះវិហារនេះ ហើយដែលត្រូវបានតុលាការយុត្តិធម៌អន្តរជាតិយកមកធ្វើជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន ។ ទូលព្រះបង្គំជាខ្ញុំ ក៏សូមថ្លែងនូវការដឹងគុណដ៏ជ្រាលជ្រៅបំផុត ថ្វាយព្រះករុណា សម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលជានិច្ចកាលព្រះអង្គតែងប្រទាននូវការគាំទ្រយ៉ាងពេញទំហឹង ចំពោះរាជរដ្ឋាភិបាលនៅក្នុងរាល់ការខិតខំ ដើម្បីបុព្វហេតុនៃការការពារអធិបតេយ្យភាពជាតិ និង បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

ជាមួយនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរ និងការវាយតម្លៃខ្ពស់ចំពោះក្រុមការងាររបស់រាជរដ្ឋាភិបាល នៅក្រោមការដឹកនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** ដែលបានខិតខំប្តូរជាកម្លាំងចិត្ត, កម្លាំងកាយ, ប្រាជ្ញា និង ស្មារតី ធ្វើការយ៉ាងសកម្ម ក្នុងរយៈពេលជាងពីរឆ្នាំកន្លងមក ដើម្បីបុព្វហេតុដ៏ថ្លៃថ្លាជាប្រវត្តិសាស្ត្រនេះ ។

បន្ថែមលើនេះ ខ្ញុំក៏សូមសំដែងនូវការវាយតម្លៃខ្ពស់ និងការដឹងគុណដ៏ជ្រាលជ្រៅបំផុតជូនចំពោះកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលបានឧទ្ទិសខ្លួន រហូតដល់បានលះបង់អាយុជីវិត និង កាយសម្បទា ដើម្បីបុព្វហេតុដ៏ឧត្តុងឧត្តមនៃការការពារអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី នៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែនកម្ពុជា ទាំងព្រំដែនគោក ទាំងព្រំដែនទឹក ពិសេស គឺនៅទិសតំបន់ប្រាសាទព្រះវិហារ ក្នុងពេលកន្លងមក ។

ខ្ញុំព្រះករុណា ខ្ញុំ ក៏សូមសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅផងដែរ ជូនដល់ប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់ដែលបានចូលរួមគាំទ្រគោលនយោបាយ និងការខិតខំនានារបស់រាជរដ្ឋាភិបាល, ទាំងជាសម្ភារៈ, ទាំងជាហិរញ្ញវត្ថុ, ទាំងជាស្មារតី, នៅក្នុងបុព្វហេតុនៃកិច្ចការពារអធិបតេយ្យភាពជាតិ និង បូរណភាពទឹកដី ។ ជាមួយនេះ ខ្ញុំសូមសំដែងនូវការដឹង-គុណជាពិសេស ជូនចំពោះបងប្អូនជាគ្រួសារនៃកងកម្លាំងប្រដាប់អាវុធ ដែលបានលះបង់

ប្តីសី កូន-ចៅ និង សាច់សាលោហិតជាទីស្រឡាញ់របស់ខ្លួន ដើម្បីបុព្វហេតុដ៏ឧត្តុងឧត្តម មិនអាចកាត់ថ្លៃបាននេះ ។

ដោយឡែក ខ្ញុំសូមថ្លែងអំណរគុណ និង សំដែងនូវការវាយតម្លៃខ្ពស់ចំពោះទូរទស្សន៍ CNC ដែលបានបញ្ជូនក្រុមការងាររបស់ខ្លួនទៅប្រចាំការនៅទីក្រុងឡាអេ នៃប្រទេសហូឡង់ ដើម្បីតាមដាន និងយកព័ត៌មាន អំពីការប្រកាសសាលដីកានេះរបស់តុលាការយុត្តិធម៌អន្តរជាតិ ផ្សាយបន្តផ្ទាល់មកព្រះរាជាណាចក្រកម្ពុជា ជូនដល់ជនរួមជាតិ និង សាធារណជនទាំងអស់បានជ្រាប ។

នៅក្នុងគ្រាដ៏សំខាន់នេះ ខ្ញុំព្រះករុណា ខ្ញុំ សូមអំពាវនាវជាថ្មីម្តងទៀត ដល់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលកំពុងបំពេញភារកិច្ចការពារព្រំដែន សូមបន្តប្រកាន់ការអត់ធ្មត់ រក្សាស្ថានភាពឈរជើងនៅដដែល និង ចៀសវាងសកម្មភាពទាំងឡាយណាដែលអាចបង្កភាពតានតឹង ឬ ការប៉ះទង្គិចជាយថាហេតុ ហើយទុកលទ្ធភាពជូនយន្តការនៃរាជរដ្ឋាភិបាលទាំងពីរ បន្តការពិភាក្សាគ្នាដើម្បីជំរុញអនុវត្តសាលដីកានេះរបស់តុលាការយុត្តិធម៌អន្តរជាតិ។ ខ្ញុំព្រះករុណា ខ្ញុំ ក៏សូមអំពាវនាវដល់ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និង បងប្អូនជនរួមជាតិទាំងអស់ មេត្តាបន្តរក្សាភាពស្ងប់ស្ងៀម, បន្តចូលរួមរក្សាសន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈនៅក្នុងប្រទេស ក៏ដូចជាបន្តរក្សា និងលើកកម្ពស់ស្មារតីនៃទំនាក់ទំនងជាអ្នកជិតខាងល្អ, សាមគ្គីភាព, មិត្តភាព, ភាពសុខដុមរមនា និង កិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធរវាងប្រទេស និង ប្រជាជនទាំងពីរ, កម្ពុជា-ថៃ, ដើម្បីផលប្រយោជន៍រួមនៃប្រជាជាតិទាំងសងខាង ទាំងសម្រាប់រយៈពេលចំពោះមុខ ទាំងសម្រាប់រយៈពេលយូរអង្វែងទៅមុខទៀត ។

**សូមអរព្រះគុណ និង សូមអរគុណ !**